00641091

E28

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| ភាគីដាក់ឯកសារ: | សហមេធាវីអន្តរជាតិរបស់អ្នកស្រី អៀង ធីរិទ្ធ |
| ដាក់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម: | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១១ |

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 01 / 02 / 2011
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្ដឹងជំទាស់របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, និង ចៅក្រម ធូ មណី**

---

**ដាក់ដោយ៖**

**សហមេធាវីអន្តរជាតិរបស់ អ្នកស្រី អៀង ធីរិទ្ធ**

កញ្ញា Diana ELLI, QC

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ្រ អង្គ

Elisabeth SIMONNEAU FORT

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

## I សេចក្ដីផ្ដើម និង សំណូមពរ

១. មេធាវីការពារក្ដីដាក់បណ្ដឹងជំទាស់ចិត្តប្រឆាំងទៅនឹងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង រួមមានចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម យូ អូត្តារ៉ា, ចៅក្រម Jean-Marc LAVERGNE និង ចៅក្រម យ៉ា សុខន និងចៅក្រមបីរូបផ្សេងទៀត ចេញពីការវិនិច្ឆ័យនៅក្នុងសវនាការជំនុំជម្រះក្ដីប្រឆាំងនឹងជនជាប់ចោទ នៅពេលខាងមុខនេះ ។ នៅរវាងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ចៅក្រមដែលមានឈ្មោះខាងលើបានដឹកនាំសវនាការជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ ឌុច (ករណី ឌុច) ដែលនៅក្នុងសវនាការជំនុំជម្រះនេះពួកគេបានសម្រេចលើបញ្ហាជាច្រើន ដែលនឹងជាបញ្ហានៅក្នុងសវនាការជំនុំជម្រះជនជាប់ចោទ ។ ការណ៍ដែលថាអង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចមកហើយនូវបញ្ហាជាក់លាក់មួយចំនួនដែលស្ថិតនៅក្នុងភាពចម្រូងចម្រាស់នៅឡើយ នឹងបង្កើតឡើងនូវភាពលម្អៀងយ៉ាងពិតប្រាកដដោយចៀសមិនផុត និងអាចប៉ះពាល់ដល់អនាគតិរបស់ចៅក្រម នៅពេលពិចារណាលើបញ្ហាជាក់លាក់នោះ ។

២. បណ្ដឹងជំទាស់ចិត្តនេះត្រូវបានធ្វើឡើងស្របតាមវិធាន ៣៤(២) នៃវិធានផ្ទៃក្នុង ដែលចែងថា៖

> ភាគីអាចធ្វើបណ្ដឹងជំទាស់ចិត្តចំពោះចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឱ្យមានភាពលម្អៀង ។

## II. ភាពអាចទទួលយកបាននៃបណ្ដឹងជំទាស់ចិត្ត

៣. អនុកថាខណ្ឌទីបីនៃវិធាន ៣៤ ចែងថា “ពាក្យបណ្ដឹងជំទាស់ចិត្តត្រូវធ្វើឡើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ” ចំណែកឯអនុកថាខណ្ឌទីទីបួននៃវិធានដដែលនេះចែងថា “ពាក្យបណ្ដឹងជំទាស់ចិត្តដែលអាចទទួលយកបាន ត្រូវតែធ្វើឡើងដើម្បីប្រឆាំងនឹងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះ នៅពេលសវនាការដំបូង[...] ។

៤. បទប្បញ្ញត្តិទាំងពីរនេះហាក់ដូចជាមានលក្ខណៈផ្ទុយគ្នា ហើយហេតុនេះ មេធាវីការពារក្ដីដាក់ពាក្យបណ្ដឹងជំទាស់ចិត្តនេះ នៅពេលនេះ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងទើបតែទទួលបានសំណុំ

រឿង ហើយដូច្នេះ អនុលោមតាមអនុកថាខណ្ឌទី៣នៃវិធាន ៣៤ ដែលតម្រូវថាពាក្យបណ្តឹងជំទាស់ត្រូវធ្វើឡើងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ ។ ដើម្បីការពារក្តីដោយយកចិត្តទុកដាក់អស់ពីចិត្ត មេធាវីការពារក្តីសូមស្នើឲ្យពិចារណាថាពេលនេះ គឺជាពេលវេលាដ៏សាក្តិសមដើម្បីដាក់បណ្តឹងជំទាស់នេះ ។ ម្យ៉ាងទៀត គេរំពឹងថានៅមុនការចាប់ផ្តើមសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចលើញត្តិដទៃទៀតដែលដាក់ដោយមេធាវីការពារក្តីរបស់ជនជាប់ចោទ និងមេធាវីការពារក្តីរបស់ជនជាប់ចោទដទៃទៀត ដែលនឹងត្រូវប៉ះពាល់ដោយអនាគតិរបស់អង្គជំនុំជម្រះសាលាដំបូង ។ ហេតុដូច្នេះ មេធាវីការពារក្តីសូមស្នើថាពាក្យបណ្តឹងជំទាស់នេះ អាចទទួលយកបាននៅដំណាក់កាលនេះនៃនីតិវិធី ។

## III. **សាធារណ**

### ៣.១ ការសំអាងហេតុលើជម្លោះប្រដាប់អាវុធ

៥. នៅក្នុងសាលក្រមរបស់ខ្លួនចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ នៅក្នុងករណី ០០១/១៨-០៧-២០០៧/អវតក/អបសជ ប្រឆាំងនឹងកាំង ហ្កេក អ៊ាវ ហៅ ឌុច (សាលក្រម ឌុច) អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជម្លោះប្រដាប់អាវុធអន្តរជាតិបានកើតមានឡើងនៅប្រទេសកម្ពុជាចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[1] ។

៦. អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិធ្វើឲ្យមានមន្ទិលសង្ស័យពីអនុភាពនៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩[2] ។

៧. មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ច្បាប់ **អវតក**)[3] ផ្តល់អំណាចឲ្យ

---

[1] សាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌទី៤២៣ ។

[2] មាត្រា២ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ ។

[3] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៃថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដាក់បញ្ចូលការធ្វើវិសោធនកម្មនានា ដែលត្រូវប្រកាសឲ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (NS/RKM/1004/006) ។

00641094



អង្គជំនុំជម្រះវិសាមញ្ញ "វិនិច្ឆ័យជនសង្ស័យទាំងអស់ ដែលបានប្រព្រឹត្ត ឬ បញ្ជាឱ្យគេប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងរធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ" ។ នេះមានន័យថា "ជនជាប់ចោទម្នាក់អាចរកឃើញថាទទួលខុសត្រូវចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរ នៅពេលដែលការបំពារបំពានធ្ងន់ធ្ងរទាំងនេះត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងមនុស្ស ឬ ទ្រព្យសម្បត្តិដែល "ត្រូវបានការពារ" ដោយអនុសញ្ញាទីក្រុងហ្សឺណែវ និងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិតែប៉ុណ្ណោះ[4] ។

៨. អង្គបុរេជំនុំជម្រះក៏បានយល់ឃើញថា ដើម្បីបង្ហាញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តម្រូវឱ្យមាននូវទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ[5] ។

៩. អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិនៅប្រទេសកម្ពុជានៅចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មិនត្រូវបានជំទាស់នៅក្នុងសំណុំរឿង០០១ ប្រឆាំងនឹង ឌុច ទេ[6]ហើយក៏មិនត្រូវបានជំទាស់នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវីរបស់ ឌុច ដែរ[7]។

១០. អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសន្និដ្ឋានខាងអង្គហេតុលើអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិនៅប្រទេសកម្ពុជាពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែលមិនត្រូវបានជំទាស់ដោយមេធាវីការពារក្តី ។ វាមិនជាការត្រឹមត្រូវទេ ការណ៍ដែលគេមិនបានចាត់ទុកចំនុចនេះបញ្ហានោះ ដោយសារអង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចផ្ទុយពីនេះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទទួលបានអំណះអំណាងដែលអាចជឿជាក់ថា ពុំមានជម្លោះប្រដាប់អាវុធអន្តរជាតិកើតឡើងនៅពេលវេលាដែលពាក់ព័ន្ធនោះ ។ មេធាវីការពារក្តីស្នើសុំដោយគោរព

---

[4] សាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌទី៤០៩ ។

[5] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១, ឯកសារ D427/2/12, នៅទំព័រទី៦ ។

[6] សាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌទី៦៣,៦៤ និង ៧៥ ។

[7] ករណី ឌុច ០០១/១៨-០៧-២០០៧/អវតក-អជសជ, ការជូនដំណឹងពីបណ្តឹងសារទុក្ខរបស់សហមេធាវី ឌុច ប្រឆាំងនឹងសាលដីកាចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៤ ខែសីហាឆ្នាំ២០១០ និងករណី ឌុច ០០១/១៨-០៧-២០០៧/អវតក-អជសជ, សារណាបណ្តឹងសារទុក្ខរបស់សហមេធាវី ឌុច ប្រឆាំងនឹងសាលដីកាចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ថាកិត្តិស័ព្ទរបស់អង្គជំនុំជម្រះវិសាមញ្ញ នឹងត្រូវបំផ្លាញ ប្រសិនបើយុត្តិធម៌មិនត្រូវបានគេមើលឃើញថាមានយុត្តិធម៌ពិតមែននោះ ។

## ៣.២ ការរសំអាងហេតុផ្សេងៗទៀត

១១. ក្រៅពីជម្លោះប្រឆាំងអាវុធអន្តរជាតិ មានបញ្ហាជាច្រើនទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយក្នុងករណី ឌុច ។ បញ្ហាទាំងនេះរួមបញ្ចូលទាំង ប៉ុន្តែមិនដាក់កម្រិត៖

- ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីយុត្តាធិការលើបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ។
- ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងលើរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ (ផ្នែក ២.២.១ នៃសាលក្រម ឌុច) ។
- ការផ្សព្វផ្សាយគោលនយោបាយ និងសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា (ផ្នែក ២.២.៧ នៃសាលក្រម ឌុច) ។
- រចនាសម្ព័ន្ធសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា (ផ្នែក ២.២.៨ សាលក្រម ឌុច) ។
- សាក្សីនៅក្នុងករណី ឌុច ត្រូវបានរំពឹងទុកថានឹងត្រូវកោះហៅឱ្យផ្តល់ជំនួយនៅក្នុងសំណុំរឿង ០០២ ជាពិសេសសាក្សីទាំងឡាយណាដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាបានផ្តល់សក្ខីកម្មដែលអាចជឿទុកចិត្តបាននៅក្នុងករណី ឌុច តែសក្ខីកម្មទាំងនោះអាចត្រូវបានជំទាស់នៅក្នុងសំណុំរឿង ០០២ ។ ឧទាហរណ៍ Dr Craig Etcheson ត្រូវបានទទួលយកជាអ្នកជំនាញនៅក្នុងករណី ឌុច ហើយគាត់ត្រូវលើកមកសំអាងនៅទូទាំងសាលក្រម ឌុច តែជំនាញរបស់គាត់នឹងត្រូវជំទាស់ដោយមេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២ ប្រសិនបើសហព្រះរាជអាជ្ញាកោះហៅគាត់ជាអ្នកជំនាញនៅក្នុងករណីនេះ[8] ។

១២. តាមការអះអាងពីខាងលើ មេធាវីការពារជនជាប់ចោទ អ្នកស្រី អៀង ធីរិទ្ធ សូមស្នើដោយគោរពថាចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម ធូ មណី, ចៅក្រម Jean-

[8] សូមមើលសំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំបដិសេធរបាយការណ៍របស់ Dr. Craig C. Etheson, ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ D192 ។

Marc LAVERGNE និង ចៅក្រម យ៉ា សុខន ដកខ្លួនចេញពីករណី ដើម្បីធានាថាមេធាវីការពារក្ដីមានឱកាសបង្ហាញអំណះអំណាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង លើបញ្ហានានាដែលត្រូវបានសម្រេចកាលពីលើកមុន រួមទាំងបញ្ហាទាក់ទងនឹងអត្ថិភាពនៃជម្លោះប្រយោជន៍អាវុធ ។

## IV. ច្បាប់នៅជាធរមាន

### ៤.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយតុលាការឯករាជ្យ និងឥតលម្អៀង

១៣. អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនៅក្នុងរឿងក្ដី *Furundzija* "សិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទម្នាក់ក្នុងការទទួលបានការជម្រះក្ដីនៅចំពោះមុខតុលាការមួយដែលឯករាជ្យ និងឥតលម្អៀង ត្រូវបានទទួលស្គាល់ជាទូទៅជាផ្នែកមួយដ៏សំខាន់បំផុតនៃលក្ខខណ្ឌតម្រូវដែលថា ជនជាប់ចោទត្រូវតែបានជំនុំជម្រះដោយយុត្តិធម៌[9] ។

១៤. សិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានដាក់បញ្ចូលនៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ[10] ។ ដូចគ្នានេះដែរ មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង[11] ចែងពីសិទ្ធិរបស់ជនជាប់ចោទ និងការធានាថាមាត្រា ១៤ និង១៥ នៃកតិកាសញ្ញាឆ្នាំ១៩៥៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ [ICCPR] ត្រូវបានគោរពនៅទូទាំងដំណើរការជំនុំជម្រះក្ដី ។ បទប្បញ្ញត្តិស្រដៀងត្រូវបានដាក់បញ្ចូលក្នុងច្បាប់បង្កើត អវតក។ អនុលោមតាមមាត្រា ៣៣ថ្មី ចែងថា "អង្គជំនុំជម្រះសាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមាន

---

[9] *ករណីរដ្ឋអាជ្ញា តទល់ជាមួយ Furundzija*, IT-95-17/1-A, សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ នៅកថាខណ្ឌទី១៧៧ ។

[10] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅខែមីនា ឆ្នាំ១៩៩៩ ។

[11] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

ការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី ហើយអង្គជំនុំជម្រះរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនិងដំណើរការសមស្របនៃច្បាប់ ដូចមានចែងនៅក្នុងមាត្រា ១៤ និង១៥ នៃកតិកាសញ្ញាឆ្នាំ១៩៥៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ មាត្រា ១៤(១) នៃ ICCPR ចែងថា "ជនគ្រប់រូបត្រូវមានភាពស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជំនុំជម្រះក្តី ។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងឥតលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ។

១៥. ដើម្បីការពារសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយតុលាការមួយដែលឯករាជ្យ និងឥតលម្អៀង កិច្ចព្រមព្រៀង ច្បាប់បង្កើត អវតក និងក្រមសីលធម៌ចៅក្រមនៅអវតក[12] លិខិតគតិយុត្តិទាំងអស់នេះមានបទប្បញ្ញត្តិទាក់ទងនឹងឯករាជ្យ និងអនាអតិរបស់ចៅក្រមនៅអវតក[13] ។ ហើយនៅក្នុងករណីដែលឯករាជ្យភាព និងភាពភាពអនាគតិរបស់តុលាការមិនត្រូវបានធានា នោះវិធាន ៣៤ នៃវិធានផ្ទៃក្នុងចែងពីយន្តការស្តារឡើងវិញនៃឯករាជ្យភាព និងភាព

---

[12] ក្រមសីលចៅក្រម អនុម័តនៅកិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងត្រូវបានធ្វើវិសោធនកម្មនៅនៅកិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានកាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ។

[13] មាត្រា ៣(៣) នៃកិច្ចព្រមព្រៀងចែងថា "ចៅក្រមគឺជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិតមានគុណសម្បត្តិ ដែលតម្រូវសម្រាប់តែងតាំងឱ្យបំរើការងារនៅការិយាល័យតុលាការនៅប្រទេសរបស់ខ្លួន ។ ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ ។ មាត្រា ១០ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចែងថា "ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងក្នុងចំណោមក្នុងតំណែងបច្ចុប្បន្នតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមនៅជាធរមាន ហើយដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត មានបទពិសោធន៍ក្នុងការងារជំនាញ ជាពិសេសខាងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិ រួមមានច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស ។ ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ ។ មាត្រា ១(១) នៃក្រមសីលធម៌ចៅក្រមចែងថា "ចៅក្រមត្រូវរក្សាឯករាជ្យភាពនៃការិយាល័យរបស់ខ្លួន និងសិទ្ធិអំណាចរបស់ខ្លួនក្នុងអង្គជំនុំជម្រះវិសាមញ្ញ ហើយត្រូវប្រតិបត្តិតាមសិទ្ធិអំណាច និងឯករាជ្យភាពក្នុងការបំពេញតួនាទីរបស់ខ្លួន ។ មាត្រា ២(១) នៃក្រមសីលធម៌ចៅក្រមចែងថា "ចៅក្រមត្រូវរក្សាភាពមិនលំអៀង និងត្រូវធានាពីការបង្ហាញពីភាពមិនលំអៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន ។

អនាគតិរបស់តុលាការៈ ការដកខ្លួនដោយចៅក្រមខ្លួនឯង ឬ បណ្តឹងជំទាស់ប្រឆាំងនឹងចៅក្រម ដោយភាគីមួយក្នុងចំណោមភាគីទាំងអស់ ។

## ៤.២ ការដកខ្លួន និង បណ្តឹងជំទាស់ចំពោះចៅក្រម

១៦. វិធាន ៣៤ ចែងថា៖

១ ចៅក្រមអាចដកខ្លួនចេញពីករណីណាមួយ ដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធដែលធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមនោះ ឬ អាចបង្កើតឱ្យមានភាពលម្អៀង ។ [...] បើសិនជាចៅក្រមជម្រះក្តីត្រូវផ្តល់ព័ត៌មានទៅអង្គជំនុំជម្រះដែលខ្លួនស្ថិតនៅ ។ ចៅក្រមដែលកំពុងមានបញ្ហាត្រូវឈប់ចូលរួមជាបន្ទាន់ ក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ។

២. ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់ពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមនោះ ឬ អាចបង្កើតឱ្យមានភាពលម្អៀង ។

[...]

៤ ប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងបញ្ហាមុនពេលជម្រះនៅពេលសវនាការដំបូង ឬ ពាក់ព័ន្ធនឹងបញ្ហាកើតឡើងក្នុងពេលជំនុំជម្រះក្តី ឬ កាលណាភាគីមិនបានដឹង នៅមុនពេលជំនុំជម្រះ នៅមុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើសំណុំរឿងនោះ[...]។

## ៤.៣ ការវាយតម្លៃពីភាពលម្អៀង

១៧. មាត្រា ៣៤(១) និង៣៤(២) ចែងថាចៅក្រមម្នាក់អាចដកខ្លួនចេញពីករណីណាមួយដោយខ្លួនឯង ឬ ភាគីណាមួយអាចធ្វើបណ្តឹងជំទាស់ "ចំពោះចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់ពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមនោះ ឬ អាចបង្កើតឱ្យមានភាពលម្អៀង ។

១៨. ការវាយតម្លៃថា តើចៅក្រមម្នាក់ពិតជាលម្អៀងឬអាចបង្កើតឱ្យមានភាពលម្អៀង ត្រូវបានសម្រេច

00641099



ដោយអង្គជំនុំជម្រះតុលាការកំពូលនៃ ICTY នៅក្នុងករណី *Furundzija*[14] និងត្រូវបានអនុម័ត ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត[15] និងអង្គបុរេជំនុំជម្រះនៅក្នុងបណ្តឹងជំទាស់ប្រឆាំង នឹងចៅក្រម ន័យ ថុល និងចៅក្រម[16] Marcel Lemonde[17] ។

១៩. អង្គជំនុំជម្រះតុលាការកំពូលនៃ ICTY បានម្រេចនៅក្នុងករណី *Furundzija* ថា[18]៖

ក. ចៅក្រមម្នាក់មិនមានភាពអនាគតិ ប្រសិនបើមានការបង្ហាញថាភាពលម្អៀងពិតប្រាកដ បានកើតឡើង ។

ខ. មានការកើតឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបាន ប្រសិនបើ

(i) ចៅក្រមជាភាគីក្នុងរឿងក្តី ឬ មានផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬមានកម្មសិទ្ធិ

---

[14] *Furundzija* កថាខណ្ឌទី១៨៩-១៩០ ។

[15] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Sam Hinga Norman*, SCSL-2004-14, សេចក្តីសម្រេចលើញត្តិសុំដកចៅក្រម Winter ពីការវិនិច្ឆ័យនៅក្នុងញត្តិលើកដំបូង ទាក់ទងនឹងការជ្រើសរើសទាហានកុមារ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ នៅកថាខណ្ឌទី ២៣ ។ ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Issa Hassan Sesay និងអ្នកដទៃទៀត*, SCSL-04-15-T, សេចក្តីសម្រេចលើញត្តិរបស់ *Sesay* និង Gbao សុំដកខ្លួនដោយស្ម័គ្រចិត្ត ឬសុំប្តឹងជំទាស់ចំពោះចៅក្រម Hon, ចៅក្រម Bankole Thomson ចេញពីករណី RUF, ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៦ នៅកថាខណ្ឌទី៥១ ។ ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Edouard Karemera និងអ្នកដទៃទៀត*, ICTR-98-44-T, សេចក្តីសម្រេចលើ ញត្តិរបស់ Karemera សុំប្តឹងជំទាស់ចៅក្រមជម្រះក្តី ចុះថ្ងៃទី២៤ ខែឧសភា ២០០៤ នៅកថាខណ្ឌទី៨ ។ ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Athanase Seromba*, ICTR-2001-66-T, សេចក្តីសម្រេចលើបណ្តឹងជំទាស់ ប្រឆាំងចៅក្រម ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ នៅកថាខណ្ឌទី ៧ ។

[16] ករណី នួន ជា សំណុំរឿង ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ០១) សេចក្តីសម្រេចជាសាធារណៈលើសំណើ ជាបន្ទាន់សុំដកចៅក្រម ន័យ ថុល ដោយរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ នៅកថាខណ្ឌទី២០-២១ ។

[17] ករណី ខៀវ សំផន សំណុំរឿង ០០២/១៣-១០-២០០៧/អវតក/កសចស (អបជ០១) សេចក្តីសម្រេចជាសាធារណៈលើ សំណើជាបន្ទាន់សុំដកចៅក្រម ន័យ ថុល ដោយរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះ អាសន្ន ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ នៅកថាខណ្ឌទី២០-២១ ។

[18] *Furundzija* កថាខណ្ឌទី១៨៩ ។

ដែលកើតចេញពីលទ្ធផលនៃករណី ឬ ប្រសិនបើការសម្រេចរបស់ចៅក្រមនឹងនាំឱ្យមានការលើកស្ទួយនូវបុព្វហេតុមួយដែលគាត់ពាក់ព័ន្ធ ជាមួយភាគីមួយក្នុងចំណោមភាគីដទៃនៃរឿងក្តី នៅក្រោមកាលៈទេសៈនេះ ការដកចៅក្រមពីករណីត្រូវធ្វើជាស្វ័យប្រវត្តិ ឬ

(ii) កាលៈទេសៈនឹងនាំឱ្យអ្នកអង្កេតឥតលំអៀង ដែលទទួលបានការជូនដំណឹងយ៉ាងត្រឹមត្រូវ យល់ពីការលម្អៀងយ៉ាងសមហេតុផល ។

២០. អ្នកអង្កេតការឥតលំអៀងនៅក្នុងផ្នែកទី២ នៅក្នុងការសម្រេចថាតើមានការកើតឡើងនៃភាពលម្អៀងដែលមិនអាចទទួលយកបាន ត្រូវតែជាមនុស្សទទួលបានការជូនដំណឹង ព្រមជាមួយការយល់ដឹងពីកាលៈទេសៈដែលពាក់ព័ន្ធទាំងអស់ រួមទាំងប្រពៃណីអំពីសុចរិតភាព និងភាពអនាគតិដែលបង្កើតផ្នែកមួយនៃព័ត៌មានជាសារវតារ ហើយបានដឹងពីការណ៍ដែលថាភាពអនាគតិ គឺជាភារកិច្ចមួយ ក្នុងចំណោមភារកិច្ចទាំងឡាយដែលចៅក្រមសច្ចាប្រណិធានថាត្រូវតែប្រកាន់ភ្ជាប់[19] ។ ករណីថ្មីៗជាច្រើនដែលតុលាការអន្តរជាតិបានពិនិត្យ ដោយប្រើមធ្យោបាយ "អ្នកអង្កេតការឥតលំអៀង" (hypothetical fair-minded observer) ពីករណី *Furundzija*[20] ។ អ្នកអង្កេតការឥតលំអៀង គឺជាមនុស្សពីខាងក្រៅ ជាអ្នកអង្កេតការ (មិនមែនជាភាគីក្នុងរឿងក្តី) ដែលទទួលស្គាល់និងយល់ដឹងពីកាលៈទេសៈគ្រប់គ្រាន់ ដើម្បីប្រាប់ថាតើយុត្តិធម៌នឹងត្រូវបានជំទាស់តវ៉ាដោយសារវត្តមានរបស់ចៅក្រមជម្រះក្តីណាមួយនៅក្នុងករណីនៅចុងបញ្ចប់ដែរ ឬអត់[21] ។ អនុលោមតាមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូហ្វាន់ដា (ICTR) នៅក្នុងករណី Karemera "យើងមិនត្រឹមតែធ្វើឱ្យមានយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែ យើងត្រូវតែធ្វើឱ្យគេមើលឃើញថាយុត្តិធម៌មែនពិតជាមាន"[22] ។

---

[19] *Furundzija* កថាខណ្ឌទី១៩០ ។

[20] *ករណីរដ្ឋអាជ្ញា តទល់ជាមួយ* *Momcilo Krajisnik*, IT-00-39-PT, សេចក្តីសម្រេចដោយចៅក្រមតែម្នាក់លើសំណើរបស់មេធាវីការពារក្តី សុំដកចៅក្រមចេញសវនាការជំនុំជម្រះ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ នៅកថាខណ្ឌទី១៤ ។

[21] *Sam Hinga Norman*, នៅកថាខណ្ឌទី២៧ ។

[22] *Maremere* នៅកថាខណ្ឌទី៨ ។ សម្រង់ចេញពីកថាខណ្ឌទី១៩៥ នៃសាលក្រមរឿងក្តី *Furundzija* នៃ ICTY ដោយបានដកស្រង់ចេញពី Lord Hewart CJ នៅក្នុងករណី *R v. Sussex Justices ex parte McCarthy*, [1924] 1 KB 256 at p. 259 ។

២១. អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសប្រទេសសៀរ៉ាឡេអូននៅក្នុងករណី Sesay បាន សម្រេចថា "នៅពេលអង្គជំនុំជម្រះសាលាដំបូងរកឃើញសញ្ញានៃភាពលម្អៀង" សេចក្តីសម្រេច សមហេតុផលនោះគឺថា ចៅក្រមត្រូវដកខ្លួនចេញពីករណី[23]។

## V. សំណើ

### ៥.១ ការកើតឡើងនៃភាពលម្អៀងរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង

២២. នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងដែលមានចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម យូ អូត្តារ៉ា, ចៅក្រម Jean-Marc LAVERGNE និង ចៅក្រម យ៉ា សុខន បានចេញសាលក្រមនៅក្នុងករណី ឌុច ដែលរកឃើញថា ឌុច មានពិរុទ្ធភាព ចំពោះបទល្មើសជាច្រើន ។ ក្នុងចំណោមបទល្មើសទាំងនោះ មានការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដែលរួមទាំងការធ្វើមនុស្សឃាតដោយចេតនា, ការធ្វើទារុណ កម្ម, ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព, ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការនិរទេស ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់[24]។ ឌុច មិនអាច ផ្តន្ទាទោសចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ បានទេ លុះត្រាតែអង្គជំនុំជម្រះសាលាដំបូងរកឃើញថាមានជម្លោះប្រដាប់អាវុធអន្តរជាតិនៅប្រទេសកម្ពុជាពី ថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ អត្ថិភាពនៃជម្លោះអាវុធ អន្តរជាតិនៅប្រទេសកម្ពុជាក្នុងអំឡុងពេលនេះ មិនត្រូវបានជំទាស់ដោយមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ ក្នុងពេលសវនាការជំនុំជម្រះឡើយ ហើយក៏មិនត្រូវបានជំទាស់នៅក្នុងបណ្តឹងសារទុក្ខ

---

សូមមើលផងដែរ *ករណីរដ្ឋអាជ្ញា តទល់ជាមួយ Théoneste Bagosora et al*, ICTR-98-41-T, សេចក្តីសម្រេចលើបណ្តឹងជំទាស់ ចិត្តចៅក្រម ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៧ នៅកថាខណ្ឌទី៧ ។

[23] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Issa Hassan Sesay និងអ្នកដទៃទៀត*, SCSL-04-15-T, សេចក្តីសម្រេចលើញត្តិរបស់ *Sesay* និង Gbao សុំដកខ្លួនដោយស្ម័គ្រចិត្ត ឬសុំប្តឹងជំទាស់ចិត្តចំពោះចៅក្រម Hon, ចៅក្រម Bankole Thomson ចេញពីករណី RUF, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ នៅកថាខណ្ឌទី១៣ ។

[24] សាលក្រម ឌុច នៅកថាខណ្ឌទី៦៧៧ ។

ប្រឆាំងនឹងសាលាដីកាចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ដែរ[25]។

២៣. ការរកឃើញអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិនៅប្រទេសកម្ពុជាពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដោយអង្គជំនុំជម្រះសាលាដំបូង មានអនុភាពយ៉ាងធំធេង ។ មានន័យថាត្រូវអនុវត្តអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អនុលោមតាមមាត្រា ២ នៃអនុសញ្ញានេះ ។ អនុលោមតាមមាត្រា ៦ អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ ការរកឃើញថាមានកើតឡើងនូវជម្លោះប្រដាប់អាវុធអន្តរជាតិនៅពេលនោះ អង្គជំនុំជម្រះសាលាដំបូងនៅពេលនេះបានធ្វើឱ្យអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អាចអនុវត្តបានគ្រប់ករណីទាំងអស់ ដែលបញ្ជូននៅចំពោះមុខអង្គជំនុំជម្រះនេះ ហើយអាចរកឃើញជនជាប់ចោទមានពិរុទ្ធភាពលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ទៀតផង ។

២៤. មេធាវីការពារក្តីលើកជាអំណះអំណាងថាពុំមានជម្លោះប្រដាប់អាវុធអន្តរជាតិនៅពេលវេលាពាក់ព័ន្ធទេ ហើយដូច្នេះ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មិនអាចអនុវត្តបានដែរ ។ ចំនុចនេះគឺជាបញ្ហាដ៏សំខាន់នៅក្នុងការជំនុំជម្រះជនជាប់ចោទ ហើយការអះអាងថាមានជម្លោះប្រដាប់អន្តរជាតិនឹងត្រូវបានជំទាស់។ តាមពិត វាជាការលំបាកក្នុងការបង្ហាញជម្លោះប្រដាប់អាវុធអន្តរជាតិ ហើយក៏ជាការអាម៉ាសផងដែរសម្រាប់អង្គជំនុំជម្រះសាលាដំបូងសម្រេចនៅក្នុងសំណុំរឿង០០២ ថាគ្មានជម្លោះប្រដាប់អាវុធអន្តរជាតិនោះ ហើយការសំអាងហេតុផ្ទុយពីនេះ នឹងបង្កើតនូវបញ្ហាគ្មានភាពឥតលំអៀង ហើយនឹងបង្កើតនូវសញ្ញាណនៃការប្រកាន់យកសេចក្តីសម្រេចលើកមុន ។ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងមានផលប្រយោជន៍លើសលុបក្នុងការធ្វើសំអាងហេតុ ដែលស្របទៅតាមការសំអាងហេតុដែលពួកគេទទួលយកនៅក្នុងការជំនុំជម្រះ ឌុច ដែលការនេះនឹងប៉ះពាល់ដល់ការសម្រេចរបស់ពួកគេលើបទល្មើសជាក់លាក់ ។ ការបណ្តែតបណ្តោយបែបនេះនឹងប៉ះពាល់ដល់កិត្តិយស់របស់ អវតក ហើយក៏អាចបង្កឱ្យគ្រោះថ្នាក់ដល់មូលហេតុ (*raison d'être*) នៃការបង្កើត អវតក ដែរ ដោយសារតែអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ គឺជាអនុសញ្ញាអន្តរជាតិមួយ

---

[25] ដូចខាងលើ នៅកថាខណ្ឌទី៦៣ និង៧៥ ។ ករណី ឌុច ០០១/១៨-០៧-២០០៧/អវតក-អជសដ, សារណាបណ្តឹងសារទុក្ខរបស់សហមេធាវី ឌុច ប្រឆាំងនឹងសាលដីកាចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ក្នុងចំណោមអនុសញ្ញាអន្តរជាតិជាច្រើន មានសារៈសំខាន់ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ ដោយរដ្ឋាភិបាល និងប្រជាជនកម្ពុជា[26] ។

២៥. នៅក្នុងករណី *Sussex Justices; ភាគីតែម្ខាង (Ex parte) McCarthy* Lord Hewart C.J. បានបញ្ជាក់ឡើងវិញនូវគោលការណ៍យុត្តិធម៌ដែលត្រូវទទួលយកតាំងពីយូរមកហើយដូចខាងក្រោម៖

ករណីជាច្រើនឱ្យបង្ហាញថាវាមិនត្រឹមតែមានសារៈសំខាន់ចំពោះមនុស្សមួយចំនួនទេ តែវាមានសារៈសំខាន់ជាសារវន្តដែលថា យើងមិនត្រឹមតែធ្វើឱ្យមានយុត្តិ ធម៌ប៉ុណ្ណោះទេ ប៉ុន្តែ យើងត្រូវតែធ្វើឱ្យគេមើលឃើញថាយុត្តិធម៌មែនពិតជាមាន[27] ។

២៦. មេធាវីការពារក្តីសូមស្នើឱ្យពិចារណាថាកាលៈទេសៈដែលលើកឡើងនៅទីនេះ នឹងនាំឱ្យអ្នកអង្កេតការឥតលំអៀង ដែលត្រូវបានជូនដំណឹងត្រឹមត្រូវ យល់ពីភាពលំអៀង ។ អ្វីដែលហៅថាអ្នកអង្កេតការឥតលំអៀង គឺជាបុគ្គលដែលមិនមែនជាភាគីក្នុងរឿងក្តី ប៉ុន្តែ បានដឹងយ៉ាងច្បាស់ពីប្រវត្តិសាស្ត្រកម្ពុជា និងជាពិសេសប្រវត្តិសាស្ត្រកម្ពុជានៃរយៈកាលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងបានដឹងពីការបង្កើត និងគោលបំណងរបស់អវតក នឹងបង្កើតជាទស្សនថាយុត្តិធម៌នឹងត្រូវបានជំទាស់ នៅពេលចៅក្រមដែលត្រូវពិចារណាពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិនៅប្រទេសកម្ពុជា នៅពេលដែលជម្លោះប្រដាប់អន្តរជាតិនេះបានសម្រេចរួចមកហើយដោយចៅក្រមទាំងនេះ នៅសវនាការជំនុំជម្រះលើកមុន ដោយមិនបានស្តាប់អំណះអំណាង ។ ប្រសិនបើអ្នកអង្កេតការឥតលំអៀងយល់ពីភាពលម្អៀងយ៉ាងពិតប្រាកដ នោះជនជាប់ចោទមិនអាចឈរនៅចំពោះមុខចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានឡើយ ហើយជនជាប់ចោទក៏មិនជំនឿថាចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចរឿងក្តី ដោយពុំទទួលឥទ្ធិពលពីសេចក្តីសម្រេចលើកមុន ទាក់ទងនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិនៅក្នុងករណី ឌុច ដែរ ។ ជនជាប់ចោទនឹងគ្មានជំនឿទុកចិត្ត ហើយដូច្នេះ ជនជាប់ចោទត្រូវបានដកហូតនូវសិទ្ធិជាសារវន្តក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌ ។

---

[26] សូមមើលបុព្វកថារបស់កិច្ចព្រមព្រៀង ។

[27] ករណី R តទល់ជាមួយ *Sussex Justices ex parte McCarthy* [1924], 1 KB 256 ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩២៣ ។

២៧. មេធាវីការពារក្តីសូមស្នើឲ្យពិចារណាថាការយល់ពីភាពលំអៀងនឹងកើតមានទៅលើចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម ធូ មណី, ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យ៉ា សុខន ។ អនុលោមតាមអង្គជំនុំជម្រះតុលាការកំពូលនៃ ICTY ក្នុងរឿង *Furundzija*[28] និងអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសប្រទេសសេរ៉ាឡេអូន (SCSL) នៅក្នុងករណី *Sesay*[29] ការយល់ពីភាពលំអៀង គឺជាមូលហេតុគ្រប់គ្រាន់សម្រាប់ឲ្យចៅក្រមម្នាក់ ឬច្រើននាក់ ដកខ្លួនចេញពីករណីដោយខ្លួនឯង ឬ ទទួលការប្តឹងជំទាស់ ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមប្តឹងជំទាស់ប្រឆាំងចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម ធូ មណី, ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យ៉ា សុខន ដើម្បីអនុញ្ញាតឲ្យជនជាប់ចោទទទួលបានការវិនិច្ឆ័យទោស ដោយគ្មានភាពលំអៀងពីអង្គជំនុំជម្រះសាលាដំបូង ។

## ៥.២ ចំនុចចាប់ផ្តើម

២៨. មេធាវីការពារក្តីទទួលស្គាល់ថាចៅក្រមនៅ អវតក "ទទួលបានសច្ចធារណ៍នៃភាពឥតលំអៀង"[30] ហើយថា "ការសន្មតនេះគឺផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តួនាទី និងគុណវឌ្ឍិរបស់ពួកគេសម្រាប់ការតែងតាំង [...] ហើយដាក់បន្ទុកមកលើភាគីក្នុងការធ្វើបណ្តឹងជំទាស់ ដើម្បីដកហូតការសន្មតនេះ[31]។ មូលហេតុសម្រាប់ការយល់ដឹងពីភាពលំអៀងប្រឆាំងនឹងជនជាប់ចោទនៅក្នុងករណី

---

[28] *Furundzija* នៅកថាខណ្ឌទី១៨៩ ។

[29] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Issa Hassan Sesay និងអ្នកដទៃទៀត*, SCSL-04-15-T, សេចក្តីសម្រេចលើញត្តិរបស់ *Sesay* និង Gbao សុំដកខ្លួនដោយស្ម័គ្រចិត្ត ឬសុំប្តឹងជំទាស់ចំពោះចៅក្រម Hon, ចៅក្រម Bankole Thomson ចេញពីករណី RUF, ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៧ នៅកថាខណ្ឌទី៥១ ។

[30] ករណី នួន ជា នៅកថាខណ្ឌទី១៥ ។

[31] ករណី នួន ជា នៅកថាខណ្ឌទី១៥ ។

គឺមិនផ្អែកលើផលប្រយោជន៍ ឬជាបក្សពួកទេ តែផ្អែកលើសាលក្រមនៅក្នុងករណីដូចគ្នា ឬករណីដាច់ដោយឡែក ដូចជាករណី *Blagojevic*[32] និងករណី *Karemera.*[33] ។

២៩. នៅក្នុងករណី *Blagojevic* មេធាវីការពារក្តីបានចោទប្រកាន់ពីភាពលំអៀងប្រឆាំងនឹងជនជាប់ចោទដោយសារតែការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងនៃ ICTY មិនអនុវត្តច្បាប់ស្តីពីការបញ្ជូនជនជាប់ចោទត្រឡប់ទៅពន្ធនាគារ ដូចដែលបានបង្គាប់ដោយអង្គជំនុំជម្រះតុលាការកំពូលនៃ ICTY ។ អង្គជំនុំជម្រះសាលាដំបូងនៃ ICTY សម្រេចថាការបដិសេធមិនអនុវត្តច្បាប់ តាមការបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូល មិនបង្កើតឱ្យមានភាពលំអៀងប្រឆាំងនឹងជនជាប់ចោទទេ ប៉ុន្តែ បានបង្កើតឱ្យមាន "ការខ្វែងគំនិតគ្នាជាមួយអង្គជំនុំជម្រះតុលាការកំពូលលើបញ្ហាច្បាប់ និងការមិនទទួលស្គាល់គ្រប់គ្រាន់លើ គោលការណ៍ដែលថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចងភ្ជាប់កាតព្វកិច្ចអង្គជំនុំ ជម្រះសាលាដំបូង"[34] ។ ការសម្រេចដោយភាន់ច្រឡំនេះមិនតម្រូវឱ្យបង្ហាញពីការដឹងពីភាពលំអៀង អនុលោមតាមអង្គជំនុំជម្រះសាលដំបូងឡើយ[35] ។

៣០. នៅក្នុងករណី *Karemera.* អង្គជំនុំជម្រះសាលាដំបូងនៃ ICTR បានសម្រេចថា៖

> ការចោទប្រកាន់ពីភាពលំអៀងលើកិច្ចដំណើរការនីតិវិធី ក៏ត្រូវបានពិចារណាដោយតុលាការកំពូលសហរដ្ឋអាមេរិក នៅករណីដែលការវាយតម្លៃពិតប្រាកដត្រូវបានធ្វើឡើង។ ជាបឋមការសម្រេចរបស់តុលាការតែឯកឯងមិនអាចបង្កើតជាមូលដ្ឋានស្របច្បាប់នោះទេ[...]។ ភាពលំអៀងជាមូលហេតុត្រឹមត្រូវសម្រាប់ការធ្វើបណ្តឹងឧទ្ធរណ៍ មិនមែនជាការដកខ្លួនចេញពីករណីទេ ។ ទីពីរ គំនិតយោបល់របស់ចៅក្រមលើមូលដ្ឋាននៃអង្គហេតុបង្កើត ឬ ព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ឬ នៅមុនកិច្ចដំណើរការនីតិវិធី មិនបង្កើតបានជាមូលដ្ឋាននៃភាពលំអៀង លុះត្រាតែភាពលំអៀងបង្ហាញពីការគាំទ្រឬប្រឆាំង ដែលធ្វើឱ្យគេមិន

---

[32] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Blagojevic* និងអ្នកដទៃទៀត IT-02-60, សេចក្តីសម្រេចលើសំណើរបស់ *Blagojevic* អនុលោមតាមវិធាន ១៥(ខ), ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ នៅកថាខណ្ឌទី១៣ ។

[33] *Karemera*, កថាខណ្ឌទី១១ ។

[34] *Blagojevic* កថាខណ្ឌទី១៥ ។

[35] ដូចខាងលើ ។

អាចធ្វើការសម្រេចឱ្យបានត្រឹមត្រូវ[36] ។

ការភាន់ច្រឡំ, បើសិនជាមាន, ផ្នែកច្បាប់ ក៏មិនគ្រប់គ្រាន់ដែរ ។ អ្វីដែលត្រូវបង្ហាញ គឺថាសេចក្ដីសម្រេចបង្កើតឱ្យមានសេចក្ដីលំអៀងប្រឆាំងនឹងភាគីដាក់ពាក្យបណ្ដឹង និងមិនពាក់ព័ន្ធជាមួយការអនុវត្តច្បាប់ឡើយ ដែលអាចមានការបកស្រាយលើសពីមួយ ឬ ការវាយតម្លៃលើអង្គហេតុដែលពាក់ព័ន្ធ[37] ។

៣១. នៅក្នុងករណី *Sesay* អង្គជំនុំជម្រះតុលាការនៃ SCSL បានសម្រេចថាអង្គជំនុំជម្រះសាលាដំបូងភាន់ច្រឡំផ្នែកច្បាប់ ដោយបានយល់ឃើញថា "សញ្ញានៃភាពលំអៀង" ដែលបានខ្លួនរកឃើញគឺមិនគ្រប់គ្រាន់ ដើម្បីបង្ហាញការយល់ពីភាពលំអៀងនោះទេ ។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការនៃ SCSL បានយល់ឃើញថាពុំមានការយល់ពីភាពលំអៀងទេ ។ មេធាវីការពារក្ដីបានខកខានបង្ហាញថា "ការវិភាគផ្នែកអង្គហេតុ និងអង្គច្បាប់របស់ចៅក្រមនៅក្នុងករណីដែលពួកគេមិនមែនជាភាគីអាចត្រូវចាត់ទុកថាបង្កើតឱ្យមានការលំអៀង"។ វាកាន់តែច្បាស់ថែមទៀតនៅពេលដែលភាគីពាក់ព័ន្ធ មិនត្រូវបានបញ្ចេញឈ្មោះ ឬ មិនឃុបឃិតជាមួយចៅក្រម[38] ។ តុលាការបញ្ជាក់ថា "វាចៀសមិនផុតទេថាមានទំនាក់ទំនងខ្លះរវាងគំនិតយោបល់របស់ចៅក្រមនៅក្នុងករណីនៅតុលាការ SCSL ពីព្រោះករណីនីមួយៗពាក់ព័ន្ធជាមួយអំឡុងពេលដូចគ្នានៃជម្លោះ ។ ប៉ុន្តែ គំនិតយោបល់របស់ចៅក្រមម្នាក់ដែលគ្រាន់តែមានទំនាក់ទំនងខ្លះជាមួយករណី មិនអាចបង្កើតឱ្យមានភាពលំអៀង ឬបង្កើតជាមូលដ្ឋាន សម្រាប់បណ្ដឹងជំទាស់ចៅក្រមផងដែរ[39] ។

---

[36] *Karemera*, កថាខណ្ឌទី១២ ។

[37] *Karemera*, កថាខណ្ឌទី១៣ ។

[38] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Issa Hassan Sesay និងអ្នកដទៃទៀត*, SCSL-04-15-T, សេចក្ដីសម្រេចលើញត្តិរបស់ *Sesay* និង Gbao សុំដកខ្លួនដោយស្ម័គ្រចិត្ត ឬសុំប្ដឹងជំទាស់ចំពោះចៅក្រម Hon, ចៅក្រម Bankole Thomson ចេញពីករណី RUF, ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ២០០៨ នៅកថាខណ្ឌទី១៤ ។

[39] ដូចខាងលើ នៅកថាខណ្ឌទី១៥ ។

៣២. មេធាវីការពារក្តីស្នើឲ្យពិចារណាថាករណីរបស់ជនជាប់ចោទ ខុសគ្នាពីករណីដែលរៀបរាប់ពីខាងលើ ។ ជាបឋម អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិនៅប្រទេសកម្ពុជាពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មិនត្រូវបានជំទាស់ក្នុងអំឡុងពេលសវនាការជំនុំជម្រះ ឌុច ឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនទទួលបានព័ត៌មានពីមេធាវីការពារក្តីដែលអាចនាំឲ្យមានការសម្រេចផ្សេង។ នេះមិនមានន័យថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសឡើយ តែអង្គជំនុំជម្រះសាលាដំបូងមិនបានស្តាប់អំណះអំណាង ដើម្បីគាំទ្រ ឬជំទាស់ការលើកឡើងថាជម្លោះប្រដាប់អន្តរជាតិមួយបានកើតឡើងនោះ ។ បើទោះបីជាការពិតថាករណីទាំងឡាយនៅចំពោះមុខ អវតក មានទំនាក់ទំនងគ្នា ពីព្រោះករណីទាំងនេះមានទំនាក់ទំនងជាមួយរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូច្នេះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅករណី ឌុច មិនអាចចាត់ទុកថាជាការយល់ឃើញរបស់ចៅក្រម ដែលជាបញ្ហានៃការជំនុំជម្រះជនជាប់ចោទ ។ ដូចដែលបានគូសបញ្ជាក់រួចមកហើយ ការសម្រេចអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ និងបញ្ហាដទៃទៀត ដែលបានដោះស្រាយរួចហើយដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី ឌុច នឹងប៉ះពាល់ដល់ករណីទាំងអស់នៅ អវតក និងជនជាប់ចោទផងដែរ ។

## ៥.៣ ការធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុលើកមុនដោយចៅក្រម

៣៣. នៅករណីរដ្ឋអាជ្ញា តទល់ជាមួយ *Nahimana* និងអ្នកដទៃទៀត អង្គជំនុំជម្រះសាលដំបូងបានដោះស្រាយនូវបញ្ហាជាច្រើន នៅពេលមេធាវីរបស់ *Nahimana* បានធ្វើបណ្តឹងជំទាស់ចិត្តប្រឆាំងនឹងចៅក្រម Philay និងចៅក្រម Mose ដោយសារពួកគេបានធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុទាក់ទងនឹងសហជនជាប់ចោទ ទាក់ទងនឹងការព្រមទទួលកំហុសរបស់គាត់នៅតុលាការ ICTR[40] ។ តុលាការ ICTR បានសម្រេចនៅក្នុងករណីនោះថា "វាមិនមែនជារឿងខុសធម្មតាទេសម្រាប់ចៅក្រមម្នាក់ចូលរួមករណីផ្សេងៗគ្នា នៅពេលដែលសាក្សីដែលផ្តល់ភស្តុតាង ដែលតម្រូវឲ្យចៅក្រមវាយតម្លៃ

---

[40] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Nahimana* និងអ្នកដទៃទៀត ករណីលេខ ICTR-99-52-I, ប្រតិចារិត, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០០០ ។

ពីភាពជឿជាក់បានដោយឯករាជ្យចំពោះសាក្សីនៅក្នុងករណីនេះ”[41]។ ការជំទាស់មួយមិនអាចផ្អែកលើការសម្រេចលើកមុនរបស់ចៅក្រមបានឡើយ[42] ។

៣៤. អ្វីខុសគ្នានៅក្នុងករណីនេះ គឺថាមិនមែនចៅក្រមតែម្នាក់នៃអង្គជំនុំជម្រះសាលាដំបូង ដែលបានចូលរួមកាលពីលើកមុនក្នុងការដោះស្រាយលើបញ្ហាអង្គហេតុដូចគ្នានោះទេ តែចៅក្រមគ្រប់ៗរូបនៃអង្គជំនុំជម្រះនេះបានសម្រេចលើបញ្ហាអង្គហេតុ ដែលបានបញ្ជាក់ពីលើ ។

## ៥.៤ សេចក្តីសន្និដ្ឋាន

៣៥. អនុលោមតាមច្បាប់អន្តរជាតិ វាមានមានសារៈសំខាន់ដែលថាមេធាវីការពារក្តីផ្តល់ឱ្យជនជាប់ចោទ មានឱកាសផ្តល់អំណះអំណាងលើករណីរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលមិនរួមបញ្ចូលចៅក្រមដែលបានសម្រេចលើបញ្ហានេះរួចមកហើយ ហើយការចូលរួមរបស់ចៅក្រមទាំងនេះ នឹងនាំឱ្យមានការយល់ពីភាពលំអៀង ។ ករណី ០០២ មានឯកសារជាច្រើនជាងឯកសារនៅក្នុងករណី ខុច រួមមានព័ត៌មានស្តីពីអត្ថិភាពនៃ ឬមិនមានជម្លោះប្រដាប់អាវុធអន្តរជាតិ ។

## VI. សេចក្តីសន្និដ្ឋាន

៣៦. យោងតាមច្បាប់អន្តរជាតិ និងច្បាប់ស្តីពីការបង្កើត អវតក ជនជាប់ចោទមានសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះដោយតុលាការឥតលម្អៀង និងឯករាជ្យ។ ដើម្បីធានាថាជនជាប់ចោទទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ចៅក្រមខ្លួនឯងផ្ទាល់ ត្រូវតែមានសីលធម៌ និងចរិតលក្ខណៈខ្ពស់ ហើយត្រូវតែធ្វើឱ្យគេសន្មតទុកជាមុនថាជាចៅក្រមឯករាជ្យ និងឥតលម្អៀង ។

---

[41] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Nahimana* និងអ្នកដទៃទៀត ករណីលេខ ICTR-99-52-I, ប្រតិចារិត, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០០០ នៅទំព័រ ១១-១២ ។

[42] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Nahimana* និងអ្នកដទៃទៀត ករណីលេខ ICTR-99-52-I, ប្រតិចារិត, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០០០ នៅទំព័រ ១៧ ។

នៅពេលឃើញថាចៅក្រមហាក់បីដូចជាមិនមានអនាគតិ ឬមិនឯករាជ្យ វិធានផ្ទៃក្នុងបានផ្តល់នូវយន្តការណ៍ដែលឱ្យចៅក្រមរូបនោះដកខ្លួនចេញពីដំណើរការនីតិវិធីដោយខ្លួនឯង ឬត្រូវប្រឈមនឹងបណ្តឹងជំទាស់ចិត្តរបស់ភាគីណាមួយ ។

៣៧. អង្គជំនុំជម្រះតុលាការកំពូលនៅ ICTY បានចែងពីបទដ្ឋានដើម្បីកំណត់ថាតើមានភាពលម្អៀងជាក់ស្តែង ឬការកើតឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបានដែរ ឬអត់ ។ វានឹងមានការកើតឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបាន ប្រសិនបើកាលៈទេសៈធ្វើឱ្យអ្នកអង្កេតការឥតលម្អៀង និងទទួលបានព័ត៌មានត្រឹមត្រូវ យល់ពីភាពលំអៀងដោយសមហេតុផល ។ ការវាយតម្លៃបែបនេះ ត្រូវបានទទួលយកដោយតុលាការអន្តរជាតិដទៃទៀត និងដោយ អវតក ផងដែរ ។ ប្រសិនបើអ្នកអង្កេតការឥតលម្អៀងដែលទទួលបានព័ត៌មានគ្រប់គ្រាន់ អាចប្រាប់ថាយុត្តិធម៌នឹងត្រូវជំទាស់ បើសិនជាមានការយល់ឃើញថាមានភាពលម្អៀងនោះ ។ វត្តមាននៃសញ្ញានៃភាពលម្អៀងនាំឱ្យមានការសន្និដ្ឋានថា ចៅក្រមត្រូវតែដកខ្លួនចេញពីនីតិវិធីដោយខ្លួនឯង ឬត្រូវប្រឈមនឹងបណ្តឹងជំទាស់ចិត្ត។

៣៨. ក្នុងសំណុំរឿង០០១ ចៅក្រម និល ណុន ចៅក្រម Sylvia Cartwright ចៅក្រម ធូ មណី ចៅក្រម Jean-Marc Lavegne និងចៅក្រម យ៉ា សុខន បានសម្រេចពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិនៅប្រទេសកម្ពុជាពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ ។ អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិនេះ មិនត្រូវបានជំទាស់ដោយមេធាវីការពារក្តី ឌុច ឡើយ ហើយក៏មិនបានជំទាស់ក្នុងដំណាក់កាលនៃបណ្តឹងសារទុក្ខដែរ។ ដូចដែលបានគូសបញ្ជាក់ពីខាងលើក្នុងករណី ឌុច ចៅក្រមដដែលនេះ បានសម្រេចលើបញ្ហាទាក់ទងនឹងអង្គហេតុជាច្រើនដែលនឹងត្រូវជំទាស់ដោយគ្មានការសង្ស័យដោយជនជាប់ចោទក្នុងសំណុំរឿង០០២។

៣៩. អាស្រ័យលើហេតុផលដូចដែលបានបញ្ជាក់ក្នុងចំនុច IV ខាងលើ មេធាវីការពារក្តីយល់ឃើញថានឹងមានការកើតឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបានប្រឆាំងនឹងជនជាប់ចោទ ដោយចៅក្រម និល ណុន ចៅក្រម Sylvia Cartwright ចៅក្រម ធូ មណី ចៅក្រម Jean-Marc Lavegne និងចៅក្រម យ៉ា សុខន ។ ការផ្តល់អំណះអំណាងថាមានអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ និងបញ្ហាអង្គហេតុសំខាន់ៗដទៃទៀតកំពុងត្រូវបានជំទាស់នោះ នឹងធ្វើឱ្យអ្នកសង្កេតការឥតលម្អៀងដែលទទួលបានព័ត៌មានពិតប្រាកដ យល់ពីភាពលំអៀងដោយសមហេតុផល ។ ដោយពិចារណាពីសារៈសំខាន់នៃសិទ្ធិសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងគោល

បំណងនៃការបង្កើត អវតក ការយល់ពីភាពលម្អៀងនេះ កើតចេញពីបញ្ហាដែលថា ចៅក្រម និល ណុន ចៅក្រម Sylvia Cartwright ចៅក្រម ធូ មណី ចៅក្រម Jean-Marc Lavegne និង ចៅក្រម យ៉ា សុខន ទំនងជាមិនអាចដឹកនាំសវនាការ និងកាត់សេចក្ដីលើរឿងក្ដីនេះ ដោយគ្មានទទួលឥទ្ធិពលពីសេចក្ដីសម្រេចលើកមុនរបស់ពួកគេក្នុងករណី ឌុច បានឡើយ ។

## VII. **សំណូមពរ**

៤០. យោងតាមវិធាន៣៤(២) នៃវិធានផ្ទៃក្នុង មេធាវីការពារក្ដីសូមដាក់បណ្ដឹងជំទាស់ប្រឆាំងចៅក្រម និល ណុន ចៅក្រម Sylvia Cartwright ចៅក្រម ធូ មណី ចៅក្រម Jean-Marc Lavegne និង ចៅក្រម យ៉ា សុខន នៅអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើការកើតឡើងនៃភាពលម្អៀង ព្រោះមានការយល់ថាមានភាពលម្អៀងប្រឆាំងជនជាប់ចោទ។

៤១. ដូច្នេះ មេធាវីការពារក្ដីស្នើឱ្យដាក់ជំនួសចៅក្រម និល ណុន ចៅក្រម Sylvia Cartwright ចៅក្រម ធូ មណី ចៅក្រម Jean-Marc Lavegne និងចៅក្រម យ៉ា សុខន ដោយចៅក្រមបម្រុងនៅអង្គជំនុំជម្រះសាលាដំបូង ឬចៅក្រមបន្ថែមដែលជ្រើសរើសដោយគណៈកម្មាធិការរដ្ឋបាលតុលាការក្នុងចំណោមចៅក្រមនៅ អវតក ដូចដែលបានចែងក្នុងវិធាន៣៤(៦) នៃវិធានផ្ទៃក្នុង។

| **ភាគី** | **កាលបរិច្ឆេទ** | **ឈ្មោះមេធាវី** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|---|
| សហមេធាវីបរទេសរបស់ អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី១ ខែ កុម្ភៈ ឆ្នាំ ២០១១ | Diana ELLIS, QC | រាជធានីភ្នំពេញ | [signature] P.P. |